៥-Mr. HIROTA YASUYUKI ឧបត្ថម្ភថវិកា ចំនួន ៣៣.៧៣០ ដុល្លារអាមេរិក សំរាប់សាងសង់ អគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម និងបង្គន់អនាម័យ ០៤បន្ទប់ នៅសាលា បឋមសិក្សា អង្គសត្វ ឃុំឈើទាល ស្រុកស្វាយរៀង ។

៦- Mr.HIGASHI SEITARO និង Mrs. FUMIKO ឧបត្ថម្ភថវិកា ចំនួន ៣៦.០០០ ដុល្លារ US ជួយសាងសង់ អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម និង បង្គន់អនាម័យ ០៥បន្ទប់ នៅអនុវិទ្យាល័យពងទឹក ឃុំពងទឹក ស្រុករំដួល ។

៧- **Ms. ICHIKAWA HIROKO** ឧបត្ថម្ភថវិកា ចំនួន ៣៣.២០០ ដុល្លារ US សំរាប់ជួយសាងសង់ អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹមគ្រប់គ្រាន់ នៅសាលាបឋមសិក្សាវត្តពោធិ៍ពិសី ឃុំពោធិរាជ្យ ស្រុកស្វាយជ្រំ ។

៨-**Okhna LEK SAMBONN** ឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារអាមេរិក

៩-**Mr. CLIFFORD LAUGHTON** ឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារអាមេរិក

១០-**Mrs. NARA LEK** ឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារអាមេរិក

១១-**Mr. WILLIAM BATDORF** ឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារអាមេរិក

សប្បុរសជន ទាំង ០៤ រូប ចុងក្រោយ បានឧបត្ថម្ភថវិកា តាមរយៈអង្គការ SAM RELIEF សំរាប់សាងសង់ អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹមគ្រប់គ្រាន់ នៅសាលាបឋមសិក្សាលក្ខ័រាជា ស្រុករំដួល ។

ខ-មេដាយសេរីវឌ្ឍនាថ្នាក់ជាតិ :

១-**Mr.JOE BROSS** ឧបត្ថម្ភថវិកា ចំនួន ៤.៦៥០ ដុល្លារអាមេរិក តាមរយៈអង្គការ SAM RELIEF សំរាប់ចូលរួមជួយសាងសង់ អគារសិក្សា នៅវិទ្យាល័យ ហ៊ុន សែន កំពង់ចក ស្រុករំដួល ។

២-**Mr. JERRY ESSENMACHER** ឧបត្ថម្ភថវិកា ចំនួន ៤.១៥០ ដុល្លារអាមេរិក តាមរយៈអង្គការ SAM RELIEF សំរាប់ចូលរួមជួយសាងសង់អគារសិក្សា នៅសាលាបឋមសិក្សាលក្ខ័រាជា ស្រុករំដួល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៦៧ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពី ការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន

-ឯកឧត្ដម ឧត្ដមសេនីយ៍ទោ **ឈឿន ចាន់ថន** អត្តលេខ ០០៣៣៦១ ជា នាយរងសេនាធិការចំរុះ បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្ដាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ១៧ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០២រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ក្នុងការចូលរួមជួយកសាង និង អភិវឌ្ឍន៍វិស័យអប់រំ នៅព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

-លោក T.C. Swartz នាយកប្រតិបត្តិករទេសចរណ៍ នៅសហរដ្ឋអាមេរិក

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

-លោកជំទាវ ជុំ ចាន់សោភា ភរិយា ឯកឧត្តម រិត ចាន់ថា

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច ✓
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៦៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការដំឡើងឋានន្តរស័ក្តិ
មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ពីអនុមន្ត្រី ទៅវរមន្ត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ស ម្រេ ច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិ លោក ខួន ពៅរាឌ្យ ពីឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ៦ ទៅឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៨ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងព្រះបរមរាជវាំង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំង ការកែសម្រួល និងការប្រគល់ភារកិច្ចជូនមន្ត្រី នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៥៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- យោងតាមសំណើរបស់ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

ស ម្រេ ច

មាត្រា ១: ត្រូវបានតែងតាំង :

១-លោក ម៉ិញ ឆានកុសល ជាជំនួយការអមប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និង បុព្វសិទ្ធិស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន

២-លោក សុខ សារាវុឌ្ឍ ជាជំនួយការអមប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៣-លោក ជុំ ហេង ជាជំនួយការអមឯកឧត្តម **ឈៀង យ៉ាណារ៉ា** អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៤-លោក អៀង សុគន្ធ ជាជំនួយការអមឯកឧត្តម ជុំ **គឹមឡេង** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៥-លោក ផាន់ ផល្លា ជាអនុប្រធានផ្នែកសិក្សា និង វិភាគគោលនយោបាយសេដ្ឋកិច្ចនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៦-លោក ធេព តិយ្យាវិទ្ធ ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៧-លោក អ៊ុំ លុយណា ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៨- លោក ស៊ីសុវត្ថិ ជួចចំនួនទោ ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង**

៩-លោក ស៊ី សុជាតិ ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

១០-លោក ហ៊ែល ចំរើន ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

១១-លោក ភាន ចន្ទមេត្តា ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

១២- លោក អ៊ិន អេម ជាអនុប្រធានផ្នែកបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

១៣-លោក នួន ទិត្យ៉ា ជាអនុប្រធានផ្នែកបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

១៤- លោក គីម ផល្លា ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

១៥-លោក ឃួន ពុំ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

១៦-លោក អ៊ឹម សុខធី ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

១៧-លោក ទៅ បុរាណ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

១៨-លោក ហុង សុភ្ជូរ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

១៩-លោក មុំ គន្ធា ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

២០-លោក ចន ណារិទ្ធ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

២១-លោក នាយ សុនឡុង ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

២២-លោក សុខ ដារ៉ា ជាសមាជិកផ្នែកសិក្សា និង វិភាគគោលនយោបាយសេដ្ឋកិច្ចនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

២៣-លោក ខួន សុមេធា ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

២៤-លោក សៀង ស៊ីថា ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

២៥-លោក ហៃ សុទ្ធន្នា ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

២៦-លោក សៀក សុគន្ធ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

២៧-លោក ខួន ម៉ារ៉ាណា ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

២៨-លោក យ៉េត ទីណែរល ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន

២៩-លោក មន្ត ថ្នាក់ថ្នា ជាសមាជិកផ្នែកបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

៣០-លោក ឈឹម ស៊ីឡេង ជាសមាជិកផ្នែកបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២: ត្រូវបានកែសម្រួលភារកិច្ចជូន:

១-លោក អ៊ុម សិទ្ធីរ៉ា ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន

២-លោក ឡាយ សុខឈៀង ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ ប្រធាននាយកដ្ឋាន

៣-លោក ខា ម៉េង ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

៤-លោក ខាន់ ចន្ណះ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

៥-កញ្ញា ស្រស់ សូរ្យអំគ្រកល្យាណនិភា ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

៦-លោក ចាន់ សុភាព ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

៧-លោក ហ៊ុខ ពៅ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

៨-លោក ឈឹស ពិនិត្យ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

៩-លោក អ៊ុម ចាន់ថុល ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **អគ្គនាយករង**

១០-លោក ឆេត តិយ៉ារិទ្ធ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

១១-លោក ឈឹម សុគន្ធារះ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**

១២-លោក ឡុង សុធារ ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន** ។

១៣-លោក យក់ ម៉ុនណា	ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**
១៤-លោក នុប សុធនវិចិត្រ	ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**
១៥-លោក ហ៊ើល សម្បត្តិ	ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន**
១៦-លោក ឈី តែសេង	ជាសមាជិកផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដោយរក្សាឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន** ។

មាត្រា ៣: ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **កើត រិទ្ធ** ជួយការងារផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ៤: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ មាត្រា ២ និងមាត្រា ៣ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រចេះ ជាប់ព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខនស/រកត/០៤៩៦/២៩ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៩១៤ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៩១៥ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង

-បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញសេចក្តីសម្រេចលេខ១៧ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-ថៃ

-បានឃើញសេចក្តីសម្រេចលេខ១៨ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-ឡាវ

-បានឃើញសេចក្តីសម្រេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម

-បានឃើញសេចក្តីសម្រេចលេខ១៤ សសរចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម

-យោងតាមតម្រូវការចាំបាច់

សម្រេច

ប្រការ១ :

ត្រូវបានបង្កើតអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុង ជាប់ព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង ចំណុះលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ២ :

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានសមាសភាពដូចខាងក្រោម :

១- អភិបាលខេត្ត ក្រុង ជាប់ព្រំដែន	ប្រធាន
២-អភិបាលរងខេត្ត ក្រុង ជាប់ព្រំដែន មួយរូប	អនុប្រធានអចិន្ត្រៃយ៍
៣-មេបញ្ជាការយោធភូមិភាគ នៃបណ្តាខេត្ត ក្រុង ជាប់ព្រំដែន	អនុប្រធាន
៤-នាយខុទ្ទកាល័យខេត្ត ក្រុង ជាប់ព្រំដែន	សមាជិក
៥-ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត ក្រុង ជាប់ព្រំដែន	សមាជិក
៦-ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង ជាប់ព្រំដែន	សមាជិក
៧-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត ក្រុង ជាប់ព្រំដែន	សមាជិក
៨-ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្រុង ជាប់ព្រំដែន	សមាជិក

៩- មេបញ្ជាការប្រតិបត្តិការសឹករងខេត្ត ក្រុង ជាប់ព្រំដែន សមាជិក
១០-មេបញ្ជាការមូលដ្ឋានទ័ពជើងទឹកខេត្ត ក្រុង ជាប់ព្រំដែន សមាជិក
១១-មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ក្រុង ជាប់ព្រំដែន សមាជិក
១២-ស្នងការនគរបាលខេត្ត ក្រុង ជាប់ព្រំដែន សមាជិក
១៣-អភិបាលស្រុក ខណ្ឌ នៃខេត្ត ក្រុង ជាប់ព្រំដែន សមាជិក
១៤-ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនអន្តរជាតិ សមាជិក
១៥-ប្រធានសាខាគយ និងរដ្ឋាករ នៅតាមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក
១៦-នាយនគរបាលអន្តោប្រវេសន៍ នៅតាមច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនអន្តរជាតិ សមាជិក
១៧-ប្រធានសាខាកាំកុងត្រូល នៅតាមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក
១៨-មេបញ្ជាការកងវរៈការពារព្រំដែន នៃកងយោធពលខេមរភូមិន្ទ ដែលឈរជើងតាមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក
១៩-នាយនគរបាលជាតិវរៈការពារព្រំដែនគោក នៃស្នងការនគរបាលខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

សមាសភាពជាក់ស្តែង នៃអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ត្រូវកំណត់ដោយដីកាសាលាខេត្ត ក្រុង សាមីនីមួយៗ ។

ប្រការ៣ :

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ជាជំនួយការឱ្យលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

១-សម្រួលការងារដល់ក្រុមប្រតិបត្តិការ និងក្រុមបច្ចេកទេសវាស់វែង ដែលចុះបំពេញបេសកកម្មក្នុងទឹកដីខេត្ត ក្រុង របស់ខ្លួន ។

២-សម្រួលការងារសាងសង់បង្គោលព្រំដែននៅលើដីជាក់ស្តែង ជាមួយខេត្តជាដៃគូ នៃភាគីម្ខាងទៀត ដោយមានការចូលរួមដឹកនាំបច្ចេកទេសពីអ្នកឯកទេស នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

៣-សិក្សា និងលើកគម្រោង ស្តីពីការអភិវឌ្ឍតាមបណ្តោយព្រំដែន ជូនលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

៤-ចូលរួមសហការជាមួយភាគីម្ខាងទៀត ក្នុងការថែរក្សាបង្គោលព្រំដែន ដែលបានបោះរួចហើយលើដីជាក់ស្តែង និងឃ្លាំមើលសភាពការណ៍មិនប្រក្រតីដែលកើតមានឡើង ដូចជា ការផ្លាស់ប្តូរទីតាំងបង្គោល ឬបង្គោលព្រំដែន ដែលមានការបែកបាក់ដោយប្រការណាមួយ និងធ្វើរបាយការណ៍មកលេខាធិការ-ដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីមានវិធានការចាំបាច់ ។

៥-ធ្វើរបាយការណ៍ជូនលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន អំពីគម្រោងអភិវឌ្ឍន៍នៃភាគីម្ខាងទៀត ដែលមានទីតាំងជាប់នឹងខ្សែព្រំដែន ដើម្បីឱ្យគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន មានវិធានការជាមួយនឹងភាគីម្ខាងទៀត ។

៦-រៀបចំទុកដាក់ និងថែរក្សាឯកសារពាក់ព័ន្ធនឹងព្រំដែន ដែលលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនប្រគល់ជូន ។

៧-ប្រមូលព័ត៌មាន ស្តីពីសភាពការណ៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រង ការឆ្លងកាត់ព្រំដែន ដែលកើតឡើងនៅតាមបណ្តោយព្រំដែនក្នុងទឹកដីនៃខេត្ត ក្រុង របស់ខ្លួន ។

៨-អនុវត្តឱ្យបានសម្រេចតាមផែនការ ទិសដៅ និងភារកិច្ច ដែលលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនប្រគល់ជូន ។

៩-ធ្វើរបាយការណ៍តាមដំណាក់កាលនីមួយៗ អំពីសភាពការណ៍ព្រំដែន និងការដោះស្រាយបញ្ហានានានៅតាមព្រំដែនក្នុងទឹកដីនៃខេត្ត ក្រុងរបស់ខ្លួន ការបោះបង្គោលព្រំដែនលើដីជាក់ស្តែង ការឆ្លងកាត់ព្រំដែន ការអភិវឌ្ឍតាមតំបន់ព្រំដែន ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

ប្រការ៤ :

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានលេខាធិការដ្ឋាន ជាសេនាធិការ ដែលមានទីតាំងនៅក្នុងសាលាខេត្ត ក្រុង នៃបណ្តាខេត្ត ក្រុងជាប់ព្រំដែន ។

លេខាធិការដ្ឋាននេះ មាននាយខុទ្ទកាល័យខេត្ត ក្រុង ជាប្រធាន និងមានមន្ត្រីជំនាញពី ៣នាក់ ទៅ ៥នាក់ ជាជំនួយការ ។

សមាសភាពជាក់ស្តែង នៃប្រធាន និងមន្ត្រីជំនាញ របស់លេខាធិការដ្ឋាននៃអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ត្រូវកំណត់ដោយដីកាសាលាខេត្ត ក្រុងសាមីនីមួយៗ ។

ប្រការ៥ :

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុងសាមី ។

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ៦ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៧ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលខេត្ត ក្រុង ដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១៣ ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៥៥....សសរ

សេចក្តីសម្រេច

ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំ រេ ច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅចូលរួមពិធីបើកពិពណ៌ចិន-អាស៊ាន លើកទី ៤ នៅទីក្រុងណាន់នីង នៃសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៧ រហូតដល់ពេលសម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល :__

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦.សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

ប្រការ ១.-

បង្កើត «គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» ហៅកាត់ «គឃាស» ដែលមានភារកិច្ចដឹកនាំរៀបចំ សម្របសម្រួលការអនុវត្ត និង តាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងមានភារកិច្ចសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ ។

ប្រការ ២.-

«គឃាស» មានសមាសភាពដូចខាងក្រោម ÷

១- រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន
២- ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា អនុប្រធាន
៣- អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអគ្គលេខាធិការនៃគណៈកម្មាធិការទីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា អនុប្រធាន
៤- អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានប្រចាំការ
៥- តំណាងរបស់គ្រប់ក្រសួង- ស្ថាប័ននៃរាជរដ្ឋាភិបាល ថ្នាក់អគ្គលេខាធិការ ឬអគ្គនាយកទទួលបន្ទុកហិរញ្ញវត្ថុ សមាជិក ។

ប្រការ ៣.-

«គហស» មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយរបស់ខ្លួន នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ជាជំនួយការនៅក្នុងការបំពេញការងារ ។ លេខាធិការដ្ឋាននេះ ត្រូវបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ប្រធាន «គហស» ។

ប្រការ ៤.-

ដើម្បីធានាប្រសិទ្ធភាពនៃការរៀបចំ ការសម្របសម្រួលអនុវត្ត និង ការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃបេសកកម្ម និងភារកិច្ចរបស់ «គហស» ដូចមានចែងក្នុងប្រការ ១ ខាងលើ គ្រប់ក្រសួង- ស្ថាប័នដែលមានការពាក់ព័ន្ធត្រូវរៀបចំបង្កើត «ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» មួយ នៅក្នុងក្រសួង- ស្ថាប័នរបស់ខ្លួន ។ ក្រុមការងារនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់មន្ត្រីតំណាងនៃក្រសួង- ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកនៅក្នុង «គហស» ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមការងារនេះ ជូនដល់គ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធ តាមសំណើរបស់ «គហស» ។ ដោយឡែក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបង្កើត «គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» មួយ ដែលត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធាន «គហស» ដើម្បីសម្របសម្រួលការរៀបចំ ការអនុវត្ត និង ការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួង ។

ប្រការ ៥.-

- «គមាស» មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងទៀតនៃក្រសួង- ស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំ ក្នុងករណីចាំបាច់

- «គមាស» មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និង តំណាងសង្គមស៊ីវិល ឱ្យចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬជាអ្នកសង្កេតការណ៍ ស្របទៅតាមតម្រូវការចាំបាច់នៃការងារ ។

ប្រការ ៦.-

- «គមាស» ធ្វើការតាមការអញ្ជើញរបស់ប្រធាន
- «គមាស» ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៨.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និង គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨ «ដើម្បីអនុវត្ត»
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ២១៣៧ ឧរថ.ភរ-ប្រក .

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៦៧៣/០៧ គ.វ.ក ចុះថ្ងៃទី២៦.០៩.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ម៉េង អៀង ហ្គាមេន ហ្វេកធើរី អិលធីឌី ចុះថ្ងៃទី១០.០៩.២០០៧

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ម៉េង អៀង ហ្គាមេន ហ្វេកធើរី អិលធីឌី (MENG IENG GARMENT FACTORY LTD.) តំណាងដោយ លោក CHUNG MING KWAN DENNIS សញ្ជាតិចិន (ហុងកុង) អាយុ៥០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H90142923 ចុះថ្ងៃទី២០.០៨.២០០២ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ម៉េង អៀង ហ្គាមេន ហ្វេកធើរី អិលធីឌី (MENG IENG GARMENT FACTORY LTD.)" មានទីតាំងស្ថិតនៅអតីតរោងចក្រតម្បាញទី៣ អាគារលេខ១ និងលេខ២ ផ្លូវលេខ៥២៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និង ត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលនឹងតម្កល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចូវនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ម៉េង អៀង ហ្គាមេន ហ្វេកធើរី អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ :...១០៤៧...ឧរថ..ករ - ប្រក.

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៦៩៧/០៧ គ.វ.ក ចុះថ្ងៃទី២៨.០៩.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អិន ប៊ី អាយ ហ្គាមេន ចុះថ្ងៃទី១៩.០៩.២០០៧

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អិន ប៊ី អាយ ហ្គាមេន (N B I GARMENT CO., LTD.) តំណាងដោយ លោក WONG PUI KWAN សញ្ជាតិចិន(ហុងកុង) អាយុ៥៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ HA9070513 ចុះថ្ងៃទី១២.០៨.២០០៥ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " អិន ប៊ី អាយ ហ្គាមេន (N B I GARMENT)" មានទីតាំងស្ថិតនៅ ភូមិត្រពាំងឈូក សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតម្កល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ " កាត់ដេរសម្លៀកបំពាក់ " ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អិន ប៊ី អាយ ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ